**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :** ១៤៧/២៥ **ក.ប/ខ.ល**

# សារលិខិតជូនពរ

## សូមគោរពជូន

## សម្តេចធម្មវិសុទ្ធវង្សា សៅ ទី ហេងសំរិន

***ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

ក្នុងឱកាសដ៏ថ្លៃថ្លានៃពិធីចម្រើនជន្មាយុគម្រប់ ៨៧ឆ្នាំ ឈានចូល ៨៨ឆ្នាំ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៥ នេះ ខ្ញុំ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមប្រសិទ្ធពរជ័យជូនចំពោះ **សម្តេចធម្មវិសុទ្ធវង្សា សៅ ទី ហេងសំរិន** ទទួលបាននូវបញ្ញាញាណភ្លឺថ្លាវាងវៃ កម្លាំងពលំមាំមួន ជន្មាយុយឺនយូរ ដែលជាកុលជីតាខ្មែរដ៏ឆ្នើមមួយរូប និងជាឧត្តមភរិយា **សម្តេចអគ្គមហាពញាចក្រី** ដ៏ប្រពៃ ជាមាតាដ៏ល្អ ដែលជានិច្ចកាលតែងតែ គាំទ្រយ៉ាងពេញទំហឹងដល់ **សម្តេចអគ្គមហាពញាចក្រី** ក្នុងការតស៊ូរំដោះប្រទេសជាតិ និងការកសាងសង្គមជាតិ ទាំងផ្នែកពុទ្ធចក្រ និងផ្នែកអាណាចក្រ កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ក៏ដូចជាការអភិវឌ្ឍប្រទេសជាតិផងដែរ។ **សម្តេច** គឺជាកម្លាំងចលករមួយយ៉ាងសំខាន់ក្នុងការជំរុញ និងលើកទឹកចិត្តដល់ **សម្តេចអគ្គមហាពញាចក្រី** ក្នុងការបម្រើជាតិមាតុភូមិ ដើម្បីឱ្យប្រទេសជាតិសម្បូរសប្បាយរុងរឿងក្នុងសន្តិភាព។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្វសាធុការពរ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរ ជូនចំពោះ **សម្តេចធម្មវិសុទ្ធវង្សា** និង**សម្តេចអគ្គមហាពញាចក្រី** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមសមប្រកបដោយព្រះពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចធម្មវិសុទ្ធវង្សា សៅ ទី ហេងសំរិន** ទទួលនូវគារវភក្តីភាពដ៏ស្មោះស្ម័គ្រពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៥

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**ហេង សួរ**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤៣៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩